00207569

A190/II/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 07 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

**បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពី សិទ្ធិ និង ភារកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ**

---

**អ្នកដាក់ឯកសារ៖**

សហមេធាវីរបស់លោក អៀង សារី

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**

អង្គបុរេជំនុំជម្រះ

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 23 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ដោយអនុលោមទៅតាម វិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារ") សូមដាក់ឯកសារបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែដែលចេញដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ចុះថ្ងៃទី ១៩ មិថុនា ២០០៨ ("ដីកាសម្រេចស្តីពីការបកប្រែ") និង ត្រូវបានជូនដំណឹងដល់ភាគីទាំងឡាយនៅថ្ងៃទី ២៣ មិថុនា ២០០៨ ។ មេធាវីការពារ បានធ្វើការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទី ២ កក្កដា ២០០៨ ដោយស្ថិតនៅក្នុងពេលវេលាកំណត់ ដូចមានចែងក្នុងវិធានផ្ទៃក្នុង ៧៥(១)។

## I. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

1. មេធាវីការពារសូមស្នើថា សំណើសុំដើមដំបូងរបស់មេធាវីការពារ ដែលបានដាក់ជូនកាលពីថ្ងៃទី ១០ មករា ២០០៨[1] បង្កើតបានជាសំណើសុំអោយបំពេញកិច្ចស៊ើបសួរ តាមវិធានផ្ទៃក្នុង ៥៥(១០)។ ការបដិសេធនូវសំណើសុំនេះដោយ ក.ស.ច.ស នៅក្នុងដីកាសម្រេចស្តីពីការបកប្រែរបស់ខ្លួនចុះថ្ងៃទី ១៩ មិថុនា ២០០៨ បង្កើតបានជាដីកាសម្រេចបដិសេធនូវសំណើសុំអោយបំពេញកិច្ចស៊ើបសួរដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង ដូច្នេះអាចប្តឹងឧទ្ធរណ៍បាន តាមវិធាន ៧៤(៣)(ខ)។

2. នៅក្នុងសំណើសុំនោះ មេធាវីការពារបានគូសចំណាំថា "បើសិនជាគ្មានជាភាសាខ្មែរចំពោះបញ្ជីនៃអាគតដ្ឋាន និង ឯកសារយោង យើងខ្ញុំមិនអាចផ្តល់នូវជំនួយខាងច្បាប់ដែលមានប្រសិទ្ធិភាព និងការតំណាងការពារក្តីអោយកូនក្តីរបស់យើងខ្ញុំគឺ លោក **អៀង សារី** បានឡើយ[2]"។ ជាលទ្ធផល ក.ស.ច.ស ត្រូវបានស្នើសុំអោយបកប្រែរាល់ឯកសារទាំងអស់ដែលបានចង្អុលបង្ហាញនៅក្នុងសំណើសុំនោះ រួមមានកំណត់សំគាល់ផ្នែកខាងក្រោមនៃទំព័រនៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ក៏ដូចជាឯកសារដទៃទៀតដែលគេយោង និងឯកសារបន្ថែមដទៃទៀតដែលបានបង្កើត និង ដែលនឹងត្រូវបង្កើតដោយ និងតាមរយៈ ក.ស.ច.ស[3] ។ នៅថ្ងៃទី ៦ ឧសភា ២០០៨ មេធាវី

---

[1] រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី ១០ មករា ២០០៨ ("សំណើសុំបកប្រែ")។

[2] សំណើសុំបកប្រែ នៅចំណុចទី ២ ។

[3] សំណើសុំបកប្រែ ចំណុចទី ៣ ។

00207571



ការពារបានដាក់ជូននូវលិខិតមួយដែលរំលឹកឡើងវិញនូវសំណើសុំរបស់ខ្លួនពីលើកមុន[4]។ នៅក្នុងលិខិតនេះ មេធាវីការពារ បានរំលឹក ក.ស.ច.ស អំពីសំណើ[5]របស់ខ្លួនពីលើកមុនសុំអោយបកប្រែឯកសារគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរជាភាសាខ្មែរ និងស្នើសុំបន្ថែមទៀតថា "រាល់ឯកសារដែលជាភាសាខ្មែរត្រូវបកប្រែជាភាសាអង់គ្លេស" [6]។ សំណើសុំទាំងពីរនេះត្រូវបានបដិសេធចោលដោយ ក.ស.ច.ស នៅក្នុងដីកាសម្រេចស្តីពីការបកប្រែរបស់ខ្លួន ចុះថ្ងៃទី ១៩ មិថុនា ២០០៨។

3. វាហាក់ដូចជាមិនមាននិយមន័យអ្វីច្បាស់លាស់ ចំពោះអ្វីដែលកំណត់បានថាជាការស្នើសុំអោយបំពេញកិច្ចស៊ើបសួរក្រោមវិធានផ្ទៃក្នុង ៥៥(១០)។ វាប្រាកដហើយថា វាមិនមានន័យក្រសោបរហូតទៅគ្រប់សំណើសុំទៅ ក.ស.ច.ស នោះទេ ដែលនេះអាចបណ្តាលអោយមានផ្លូវជាច្រើនក្នុងការប្តឹងឧទ្ធរណ៍ដែលមិនចាំបាច់។ ប៉ុន្តែ មេធាវីការពារសូមស្នើថា កិច្ចស៊ើបសួរមួយដាច់ខាតមិនត្រូវបកស្រាយក្នុងន័យចង្អៀតបែបនោះទេ ដែលនេះនឹងរារាំងពីមេធាវីការពារពីមធ្យោបាយដើម្បីតតាំងដោយពិតប្រាកដនូវសេចក្តីសម្រេចទាំងឡាយរបស់ ក.ស.ច.ស ដែលទាក់ទងនឹងរបៀបប្រព្រឹត្តទៅនៃកិច្ចស៊ើបសួរដោយតុលាការ។ ហេតុដូច្នេះ មេធាវីការពារសូមស្នើថា អត្ថន័យដ៏សមហេតុផលចំពោះកិច្ចស៊ើបសួរ គឺថាវាជាកិច្ចមួយដែលមានផលប៉ះពាល់ដល់ខ្លឹមសារនៃកិច្ចស៊ើបសួរ។ នេះមានន័យយ៉ាងជាក់លាក់ថា ជាកិច្ចអ្វីមួយដែលទាក់ទងដល់ការប្រមូលភស្តុតាងដែលនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងដែលជាប់ទាក់ទិនដល់ភាពមានពិរុទ្ធ ឬ ភាពគ្មានកំហុស។

4. ការបដិសេធដោយ ក.ស.ច.ស មិនបង្គាប់អោយបកប្រែនូវឯកសារចោទប្រកាន់គាំទ្រនូវពិរុទ្ធភាពរបស់លោក អៀង សារី បង្កើតបានជាការបដិសេធមិនបំពេញកិច្ចមួយដែលនឹងត្រូវបន្ថែមភស្តុតាងទៅក្នុងសំណុំរឿង។ ហេតុដូច្នេះ វាជាការបដិសេធមិនបំពេញកិច្ចស៊ើបសួរ ហើយអាចប្តឹងឧទ្ធរណ៍បានក្រោមវិធាន ៧៤(៣)(ខ)។

5. បើសិននិយមន័យចង្អៀតជាងនេះនៃកិច្ចស៊ើបសួរអាចត្រូវបានគេប៉ាន់ស្មានបាន វិធានផ្ទៃក្នុងគួរត្រូវចែងជាក់លាក់អំពីនិយមន័យបែបនេះ។ ជំនួសអោយការប្រើឃ្លា "សំណើសុំអោយបំពេញកិច្ច

---

[4] រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតទៅសហចៅក្រមស៊ើបអង្កេតមានចំណងជើងថា "កង្វះការឆ្លើយតបទៅនឹង សំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ទៅជាភាសាខ្មែរ និងអង់គ្លេស" ចុះថ្ងៃទី ៦ ឧសភា ២០០៨ ("លិខិតថ្ងៃ ៦ ឧសភា ២០០៨").

[5] លិខិតថ្ងៃ ៦ ឧសភា ២០០៨ កថាខណ្ឌទី ១ ។

[6] លិខិតថ្ងៃ ៦ ឧសភា ២០០៨ កថាខណ្ឌទី ៦ ។

ស៊ើបសួរ" វិធានផ្ទៃក្នុងគួរប្រើពាក្យសំណើសុំសម្ភាសសាក្សី ឬ សំណើសុំអោយស៊ើបសួរប្រឆាំងការចោទប្រកាន់ជាក់លាក់ណាមួយ។ ប៉ុន្តែ និយមន័យដ៏ចង្អៀតបែបនេះគឺពិតជាត្រូវបានគេបដិសេធ ដោយហេតុថាវាស្តែងឡើងជាដាក់កំរិតយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពរបស់ ក.ស.ច.ស ក្នុងការបំពេញការស៊ើបសួរ ។ ហេតុដូច្នេះ មាន តែការបកស្រាយទូលំទូលាយចំពោះកិច្ចស៊ើបសួរទេ ទើបជាការសមរម្យតាមរយៈការពង្រីក ដែលផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍ទូលំទូលាយក្រោមវិធានផ្ទៃក្នុង ៧៤(៣)(ខ)។

6. មេធាវីការពារក៏សូមស្នើផងដែរថា ដោយសារសារជាតិនៃបណ្តឹងឧទ្ធរណ៍នេះ វាមិនចាំបាច់អោយមានសវនាការដេញដោលផ្ទាល់មាត់ទេ ហើយវាគួរត្រូវបានសំរេចឈរលើមូលដ្ឋានត្រឹមតែសារណាជាលាយលក្ខអក្សរបានហើយ។

## II. សេចក្តីសង្ខេបនៃអំណះអំណាង

7. មេធាវីការពារសូមស្នើថា ដីកាសម្រេចស្តីពីការបកប្រែនេះរំលោភសិទ្ធិរបស់លោក អៀង សារី ដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួន[7] ដែលមានផ្លូវមួយគត់ដែលសិទ្ធិអាចនឹងត្រូវបានការពារ បើសិនជាគាត់មានលទ្ធភាពពិនិត្យមើលភស្តុតាងដែលដាក់បញ្ចូលមកប្រឆាំងនឹងគាត់ ជាភាសាដែលគាត់អាចយល់បានទាំងស្រុង នោះគឺជាភាសាខ្មែរ។ ដីកាសម្រេចនេះក៏រំលោភបំពានផងដែរនូវសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការតំណាងការពារក្តី[8]ដោយមានប្រសិទ្ធិភាព ដែលវារារាំងមេធាវីបរទេសរបស់គាត់មិនអោយមានលទ្ធភាពពិនិត្យ និងវិភាគភស្តុតាងប្រឆាំងនឹងកូនក្តីរបស់ខ្លួន ជាភាសាដែលមេធាវីនោះយល់ដឹងបាន គឺភាសាអង់គ្លេស។

8. ជាងនេះទៅទៀត ប្រព័ន្ធដែលដាក់បន្ទុកដោយ ក.ស.ច.ស មកលើមេធាវីការពារដើម្បីអោយធ្វើការបកប្រែក្នុងដំណាក់កាលស៊ើបសួរ គឺជាក់ស្តែងបញ្ច្រាសនូវបន្ទុកទទួលខុសត្រូវរៀបចំការបកប្រែដោយអាជ្ញាធររបស់រដ្ឋ ដែលបង្កសំណុំរឿង និងធ្វើការស៊ើបអង្កេតរឿងក្តីប្រឆាំងនឹងលោក អៀង សារី ដែលមានស្ថាប័នដូចជា ក.ស.ព និង ក.ស.ច.ស ហើយបង្វិលបន្ទុកនេះមកលើលោក

---

[7] សំណើសុំបកប្រែ ចំណុចទី ២ និង លិខិតថ្ងៃ ៦ ឧសភា ២០០៨ កថាខណ្ឌ ៤ "ការបកប្រែឯកសារទៅជាភាសាសំរាប់ប្រើការរបស់លោក អៀង សារី គឺមានសារៈសំខាន់ ប្រសិនបើគាត់ត្រូវអនុវត្តសិទ្ធិរបស់គាត់ឲ្យបានពេញលេញដើម្បីចូលរួមការពារដោយផ្ទាល់ខ្លួន"

[8] សំណើសុំបកប្រែ ចំណុចទី ២ ។

អៀង សារី និងក្រុមមេធាវីការពារក្ដីរបស់គាត់ទៅវិញ។ នេះបង្កើតទៅជាការរំលោភបំពានគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្ដីគ្នា (equality of arms) ។

## III. អំណះអំណាង

### A. ការបកប្រែឯកសារទៅជាភាសារបស់លោក អៀង សារី

9. ក.ស.ច.ស បានយល់ឃើញថា "តុលាការព្រហ្មទណ្ឌអន្តរជាតិជាច្រើន បានពឹងផ្អែកលើយុត្តិសាស្ត្រ ទាក់ទិននឹងមាត្រា ៦(៣)(ង) នៃតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស [...] ដែលកំណត់ថា ជនត្រូវចោទ មិនអាចទាមទារអោយមានការបកប្រែជាសរសេរនូវរាល់វត្ថុតាងសរសេរ ឬឯកសារផ្លូវការទាំងអស់នៅក្នុងសំណុំរឿង ជាភាសារបស់ខ្លួនបានឡើយ៖ ប៉ុន្តែតម្រូវការដែលចាំបាច់នោះគឺ អនុញ្ញាតអោយជនត្រូវចោទមាន "ការយល់ដឹងពីសំណុំរឿងដែលចោទប្រកាន់ខ្លួន និងអាចការពារខ្លួនឯងបាន ជាពិសេសអាចបកស្រាយអំពីអង្គហេតុជូនតុលាការបាន[9]" "។ ផ្អែកលើសំអាងហេតុទាំងនេះ ក.ស.ច.ស យល់ឃើញថា ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែជាខ្មែរ ត្រឹមតែឯកសារដូចតទៅនេះ៖

១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (Indictment) របស់សហចៅក្រមស៊ើបអង្កេត តាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដែលគេអោយឈ្មោះថា ដីកាដំណោះស្រាយ

២) ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ (Indictment) នេះសំអាងទៅលើ

៣) ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ

---

[9] ដីកាសម្រេចស្ដីពីការបកប្រែ ចំណុច ៤ *ដោយស្រង់យកមកសំអាង* រឿងក្ដី Luedicke, Belkacem et Koc តទល់នឹង ប្រទេសអាល្លឺម៉ង់ សាលក្រមចុះថ្ងៃទី ២៨ វិច្ឆិកា ១៩៧៨ Series A no 29, § 48 និង រឿងក្ដី Kamasinski តទល់នឹង ប្រទេសអូទ្រីស សាលក្រមចុះថ្ងៃទី ១៩ ធ្នូ ១៩៨៩ Series A no. 168, §74, Muhimana§§16-17, និងរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Lubanga*, ICC-01/04-01/06, សេចក្ដីសំរេចចុះថ្ងៃទី ៤ សីហា ២០០៦ ។

៤) ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា ក៏ដូចជាកំណត់សំគាល់ផ្នែកខាងក្រោមនៃទំព័រ និង លិបិក្រមនៃធាតុផ្សំខាងអង្គហេតុដែលដីកាទាំងនោះសំអាងទៅលើ[10]

10. បច្ច័យដ៏សមហេតុផលកើតចេញពីការសំរេចបែបនេះគឺថា ឯកសារដូចខាងក្រោមនេះនឹងមិនត្រូវបានបកប្រែទៅជាភាសាខ្មែរទេ៖

១) ឯកសារដែលមាននិយាយនៅក្នុងកំណត់សំគាល់ផ្នែកខាងក្រោមនៃទំព័ររបស់ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា

២) ឯកសារទាំងឡាយដែលត្រូវបានប្រមូលចងក្រងដោយ ក.ស.ច.ស ដែលមិនបង្កើតបានជា "ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព" ដូច្នេះវានឹងជម្រុះចោលនូវភស្តុតាងដោះបន្ទុក

11. មេធាវីការពារសូមស្នើថា សេចក្ដីសំរេចបែបនេះរំលោភបំពានសិទ្ធិរបស់លោក អៀង សារី ដើម្បីចូលរួមក្នុងកិច្ចការពារក្ដីរបស់ខ្លួន ។ នេះរួមបញ្ចូលសិទ្ធិចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយ និង ទាំងអស់ ដោយមានលទ្ធភាព៖ យល់ដឹងពីប្រភេទនៃបទចោទប្រកាន់ យល់ដឹងអំពីកិច្ចដំណើការនៃនីតិវិធី យល់ដឹងអំពីសេចក្ដីលំអិតនៃភស្តុតាង ពិភាក្សាជាមួយមេធាវីឬជាជំនួយដល់កិច្ចការពារក្ដីរបស់ខ្លួន និងយល់ដឹងពីបច្ច័យនៃកិច្ចដំណើរការនីតិវិធី[11] ។ ប៉ុន្តែ ការប្រើប្រាស់សិទ្ធិនេះពឹងផ្អែកទៅលើការបង្ហាញភស្តុតាងប្រឆាំងនឹងលោក អៀង សារី ដែលដាក់ជូនដោយ ក.ស.ព ជាភាសាដែលគាត់អាចយល់ គឺភាសាខ្មែរ ។ ភស្តុតាងក៏ដាច់ខាតត្រូវបានគេផ្ដល់ជូនផងដែរ នៅពេលយ៉ាងឆាប់បំផុតនៅក្នុងអំឡុងពេលកិច្ចស៊ើបសួរ ដើម្បីអោយគាត់អាចមានពេលគ្រប់គ្រាន់ដើម្បីប្រើប្រាស់នូវភស្តុតាងនោះបានដោយត្រឹមត្រូវ។ ការកម្រិតការបកប្រែជាភាសាខ្មែរត្រឹមតែដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ និង លេខយោង ប៉ុន្តែមិនមែនឯកសារ

---

[10] ដីកាសម្រេចស្ដីពីការបកប្រែ ចំណុច ៥ ។

[11] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Strugar*, IT-01-42-T, សេចក្ដីសម្រេចលើពាក្យសុំរបស់មេធាវីការពារសុំអោយបញ្ចប់នីតិវិធី ចុះថ្ងៃទី ២៦ ឧសភា ២០០៤ កថាខណ្ឌ ៣៦ ។ *សូមមើលផងដែរ Lagerblom តទល់នឹងប្រទេសស៊ុយអែដ* តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ចុះថ្ងៃទី ១៤ មេសា ២០០៣ កថាខណ្ឌ ៤៩ កំណត់ថា មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបសំរាប់សិទ្ធិមនុស្ស "ធានាសិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមដោយមានប្រសិទ្ធិភាពនៅក្នុងការជំនុំជម្រះក្ដីព្រហ្មទណ្ឌ"។

ដែលគាំទ្រនោះខ្លួនឯងដែលវាត្រូវបានគេពឹងផ្អែកទៅលើ រារាំងលោក អៀង សារី មិនអោយមានឱកាសដើម្បីពិនិត្យអោយគ្រប់ជ្រុងជ្រោយ ធ្វើវិភាគ និងធ្វើការប្រើប្រាស់នូវភស្តុតាងដែលប្រឆាំងនឹងគាត់។ ជាលទ្ធផល គាត់មិនអាចប្រើប្រាស់អោយអស់លទ្ធភាពនូវសិទ្ធិជាមូលដ្ឋាននេះ។

12. មេធាវីការពារម្តងហើយម្តងទៀតបានទាញចំណាប់អារម្មណ៍ ក.ស.ច.ស និង អង្គបុរេជំនុំជម្រះ អំពីសារៈសំខាន់នៃសិទ្ធិនេះ និងការពិតដែលថាលោក អៀង សារី មានបំណងយ៉ាងពេញលេញដើម្បីអនុវត្តសិទ្ធិនេះនៅចំពោះមុខ អ.វ.ត.ក[12] ។ នៅក្នុងដីកាសម្រេចស្តីពីការបកប្រែ ក.ស.ច.ស

---

[12] *សូមមើល* រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស អនុស្សារណៈផ្ទៃក្នុង មានចំណងជើង "កិច្ចប្រជុំថ្ងៃទី ១៨ ធ្នូ ២០០៧" ចុះថ្ងៃទី ២០ ធ្នូ ២០០៧ ។ រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី ១០ មករា ២០០៨ "*ដូចបានជំរាបជូនពីមុននៅក្នុងការពិភាក្សារបស់យើងខ្ញុំជាមួយសហចៅក្រមស៊ើបអង្កេត រួមទាំងលិខិតឆ្លើយឆ្លង លោក អៀង សារី* ***<u>មានចេតនាជាខ្លាំងក្នុងការជួយក្រុមការងារច្បាប់របស់គាត់ក្នុងការត្រៀមរៀបចំកិច្ចការពារក្តីរបស់គាត់</u>***"។ រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) សំណើសុំបន្ទាន់សុំអោយពន្យារពេលអោយបានសមស្របដើម្បីដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ និង ការឆ្លើយតបទៅនឹងសារណារបស់ការិយាល័យសហព្រះរាជអាជ្ញា យោងតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៨ កុម្ភៈ ២០០៨ កថាខណ្ឌ ២៤ ២៦ ដល់ ២៧ "លោក អៀង សារី មានសិទ្ធិមិនគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយ និង ទាំងអស់ប្រឆាំងនឹងរូបគាត់ ដែលរួមមានផ្សេងៗពីនេះគឺ សិទ្ធិមានវត្តមាននិងជួយផ្តល់យោបល់ក៏ដូចជាសិទ្ធិស្តាប់និងតាមដានកិច្ចដំណើរការនីតិវិធី" ។ រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) សំណើបន្ទាន់របស់លោក**អៀង សារី** សុំអោយមានការបន្ថែមចំនួនទំព័រសារណានិងការពន្យារពេលនៃការដាក់សារណា ចុះថ្ងៃទី ១២ មីនា ២០០៨ កថាខណ្ឌ ២៥ "អង្គបុរេជំនុំជម្រះបានដឹងថា អៀង សារី បានសម្រាកនៅក្នុងមន្ទីរពេទ្យនៅថ្ងៃទី ១៣ មីនា និងបានដឹងថា ការត្រៀមរៀបចំសារណារបស់មេធាវីស្តីពីយុត្តាធិការ "<u>ត្រូវការការចូលរួមសកម្ម និងជាប់លាប់ពីលោក អៀង សារី</u>" ដែលជាការអនុវត្តនូវ "សិទ្ធិគ្មានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមប្រកបដោយប្រសិទ្ធិភាពក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយ និងទាំងអស់ប្រឆាំងនឹងគាត់" ។ រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំឲ្យអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យ សុខភាពលោក **អៀង សារី** ដើម្បីសម្រេចពីសម្បទាក្នុងការចូលរួមក្នុងសវនាការ ចុះថ្ងៃទី ១៤ មីនា ២០០៨ កថាខណ្ឌ ៦ "លោក អៀង សារី មានសិទ្ធិឥតគុណវុឌ្ឍិមួយ ដើម្បីចូលរួមប្រកបដោយប្រសិទ្ធិភាពនៅក្នុងដំណើរការរឿងក្តីណាមួយ ឬទាំងអស់ ដែលប្រឆាំងមកលើរូបគាត់ ដែលក្នុងចំណោមសិទ្ធិជាច្រើនទៀត រួមមាន សិទ្ធិមានវត្តមាន និងសិទ្ធិទទួលជំនួយពីឬផ្តល់ជំនួយដល់មេធាវី ក៏ដូចជាសិទ្ធិក្នុងការស្តាប់ និង តាមដានដំណើការរឿងក្តី" ។ រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតទៅក.ស.ច.កកង្វះការឆ្លើយតបនឹង "សំណើសុំអោយមានកោសល្យវិច្ច័យផ្នែកចិត្តសាស្ត្រចំពោះលោក **អៀង សារី** ដើម្បីកំណត់ភាពសមស្របក្នុងការចូលរួមក្នុងសវនាការ" ដែលបានដាក់ជូនកាលពីថ្ងៃទី ១៤ មីនា ២០០៨ ចុះថ្ងៃទី ១៩ មិថុនា ២០០៨ កថាខណ្ឌ ២ "សិទ្ធិ<u>ចូលរួមក្នុងកិច្ច</u>

បានទទួលស្គាល់នូវសិទ្ធិដ៏ច្រើនលើសលប់ ដែលប្រហែលជាទាក់ទងទៅតែនឹងការសម្រេចអំពីកាតព្វកិច្ចបកប្រែឯកសារគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ[13] ។ ទំនងជាគួរឲ្យចាប់អារម្មណ៍តាមរយៈការអវត្តមានអំពីសិទ្ធិមួយ គឺសិទ្ធិរបស់ជនត្រូវចោទដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួន ថ្វីបើការពិតដែលថា លោក អៀង សារី បានស្នើសុំយ៉ាងជាក់លាក់នូវសិទ្ធិនេះ ដោយស្នើសុំបកប្រែនូវឯកសារទាំងឡាយជាភាសាខ្មែរ។

13. វាច្បាស់លាស់ហើយថា សិទ្ធិរបស់លោក អៀង សារី ក្នុងចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួនមិនមែនជាសិទ្ធិមួយត្រូវបានពិចារណាថាមានសារៈសំខាន់ដោយ ក.ស.ច.ស ឡើយ។ នេះគឺច្បាស់លាស់ហើយចេញពីការខកខានមិនបានឆ្លើយតបរបស់ ក.ស.ច.ស ទៅនឹងសំណើសុំរបស់មេធាវីការពារអោយមានអ្នកឯកទេសផ្នែកចិត្តសាស្ត្រពិនិត្យលោក អៀង សារី ដែលបានដាក់ពាក្យសុំកាលពីថ្ងៃទី ១៤ មីនា ២០០៨[14]។ ជាងនេះទៅទៀត នៅក្នុងសេចក្តីសម្រេចលើសំណើរបស់លោក នួន ជា សុំអោយតែងតាំងអ្នកធ្វើកោសល្យវិច្ច័យផ្នែកចិត្តសាស្ត្រ ក.ស.ច.ស ពិចារណាថា បញ្ហានៃភាពសមស្របរបស់កូនក្តីលោកសម្រាប់ការកាត់ទោសនោះ “មិនអាចលើកឡើងនៅដំណាក់កាលនេះទេ ដោយសារថាការបញ្ជូនកូនក្តីរបស់លោកទៅកាត់ទោស មិនមែនជាបញ្ហាដែលត្រូវលើកឡើងនៅដំណាក់កាលនេះនោះទេ”។ ធម្មតា វាទំនងជាថា ក.ស.ច.ស មិនពិចារណាថា សិទ្ធិដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួន ចាំបាច់ត្រូវទទួលបានការគាំទ្រនៅក្នុងអំឡុងពេលនៃនីតិវិធីស៊ើបសួរ។

---

<u>ការពារខ្លួនរបស់បុគ្គលម្នាក់</u> គឺជាសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទ និង ត្រូវបានធានាដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងត្រូវបានគាំទ្រដោយលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន ដូចដែលមាននិយាយពិស្តារនៅក្នុងសំណើសុំនោះ” ។

[13] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ៣ ក.ស.ច.ស បានគូសចំណាំនូវសិទ្ធិទទួលបានការជូនដំណឹងឆាប់រហ័ស និងជាលំអិតជាភាសាដើម្បីជនត្រូវចោទអាចយល់ដឹងពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់មកលើខ្លួន សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការការពារខ្លួន សិទ្ធិមាន "សមភាពនៃមធ្យោបាយតទល់ក្តីគ្នា" (equality of arms) សិទ្ធិពិនិត្យភស្តុតាងដាក់បន្ទុក និង សិទ្ធិមានជំនួយពីអ្នកបកប្រែភាសាដោយមិនមានការបង់ថ្លៃ ប្រសិនបើជនត្រូវចោទមិនអាចយល់ ឬមិនអាចនិយាយភាសាដែលប្រើនៅក្នុងតុលាការ។

[14] សូមមើល រឿងក្តី **អៀង សារី** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំឲ្យអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យ សុខភាពលោក **អៀង សារី** ដើម្បីសម្រេចពីសម្បទាក្នុងការចូលរួមក្នុងសវនាការ ចុះថ្ងៃទី ១៤ មីនា ២០០៨ ។ បន្ទាប់ពីសំណើសុំនេះមិនត្រូវបានឆ្លើយតបអស់រយៈពេលជាងបីខែ មេធាវីការពារបានដាក់ពាក្យ “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសកម្មភាពដែលមានគោលដៅបដិសេធដោយចេតនារបស់ ក.ស.ច.ស ទៅលើសំណើសុំឲ្យអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យសុខភាពលោក **អៀង សារី** ដើម្បីសម្រេចពីសម្បទាក្នុងការចូលរួមក្នុងសវនាការ” នៅថ្ងៃទី ២ កក្កដា ២០០៨ ។

14. ដីកាសម្រេចនេះក៏កម្រិតផងដែរនូវការបកប្រែជាភាសាខ្មែរនូវ "ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព[15]"។ ការជាប់ជំពាក់ជំពិនដែលមានសារៈសំខាន់នេះគឺថា ភស្តុតាងដែលជាផ្នែកនៃសំណុំរឿង ប៉ុន្តែវាមិនមែនជាភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធ (ចំពោះភស្តុតាងដែលមិនត្រូវបានអះអាងថាបានបង្ហាញពីភាពមានពិរុទ្ធរបស់ជនត្រូវចោទ) មិនចាំបាច់ត្រូវបានបកប្រែជាភាសាខ្មែរ ជាភាសារបស់លោក អៀង សារី ឡើយ។ ដូច្នេះ វាជម្រុះចេញនូវភស្តុតាងដោះបន្ទុកពីឯកសារដែលមានភាពមិនច្បាស់លាស់ដែលនឹងត្រូវបកប្រែ។

15. ក.ស.ច.ស ពឹងផ្អែកទាំងស្រុងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTR និង ICTY[16] ដើម្បីធ្វើយុត្តិកម្មនូវការកំរិតនេះ។ ប៉ុន្តែ អ.វ.ត.ក មិនយកតាមនីតិវិធីដដែលដែលជាប្រព័ន្ធ ចោទប្រកាន់នៅតុលាការ ICTR និង ICTY ឡើយ ។ យុត្តិសាស្ត្ររបស់តុលាការពិសេសចំពោះកិច្ច (ad hoc) នេះមិនអាចអនុវត្តដោយផ្ទាល់ចំពោះស្ថានភាពនៅ អ.វ.ត.ក ឡើយ។ ហើយករណីនេះវាគឺជារឿងមួយនៅពេលដែលបញ្ហាដែលទាក់ទងនឹងយុត្តិសាស្ត្រដែលមិនអាចកែកុនបាន ពីប្រភេទនៃប្រព័ន្ធយុត្តិធម៌ ដែលកំពុងប្រើប្រាស់សព្វថ្ងៃ។

16. នៅតុលាការ ICTY និង ICTR ដំណាក់កាលស៊ើបអង្កេតគឺមានភាពខុសគ្នាពីដំណាក់កាលដូចគ្នានេះនៅ អ.វ.ត.ក ។ នៅតុលាការទាំងពីរ ICTY និង ICTR ដីកាចោទប្រកាន់គឺតាក់តែងឡើងដោយរដ្ឋអាជ្ញា បន្ទាប់ពីសេចក្តីសំរេចដែលថាមានករណី*អង្គហេតុដំបូងដែ (prima facie case)* កើតមានឡើង ដែលក្រោយមកត្រូវបញ្ជូនទៅចៅក្រមម្នាក់នៃតុលាការជាន់ដំបូងនៃអង្គជំនុំជម្រះ[17]។ ដីកាចោទប្រកាន់ និងឯកសារគាំទ្របន្ទាប់មកត្រូវបានត្រួតពិនិត្យដោយចៅក្រមនៃអង្គបុរេជំនុំជម្រះ ហើយបើសិនចៅក្រមនេះយល់ស្របតាមថាមាន ករណី*អង្គហេតុដំបូងដែ (prima facie case)* ត្រូវបានរកឃើញ ចៅក្រមនោះត្រូវតែអះអាងបញ្ជាក់នូវដីកាចោទប្រកាន់ហើយ "ចេញសេចក្តីសំរេចចោទប្រកាន់ និងដីកាចាប់ខ្លួន ឃុំខ្លួន បង្គាប់អោយចូលសារភាព ឬ

---

[15] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ៥ ។

[16] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Delalić*, IT-96-21, សេចក្តីសំរេចលើពាក្យសុំរបស់មេធាវីការពារអោយបញ្ជូនឯកសារមកជាភាសារបស់ជនជាប់ចោទ ចុះថ្ងៃទី ២៥ កញ្ញា ១៩៩៦ កថាខណ្ឌ ៨ ។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ljubičić*, IT-00-41, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារសុំអោយបកប្រែឯកសារទាំងអស់ ចុះថ្ងៃទី ២០ វិច្ឆិកា ២០០២ ("សេចក្តីសម្រេចករណី *Ljubičić*") ។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Muhimana*, ICTR-95-1-B-I, សេចក្តីសម្រេច ចុះថ្ងៃទី ៦ វិច្ឆិកា ២០០១ ។

[17] មាត្រា ១៨(៤) នៃច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY

ផ្ទេរនូវបុគ្គលនោះ[18]"។ បន្ទាប់វាមានបន្តបន្ទាប់នូវដំណាក់មុនអង្គសេចក្តីដែលជាញឹកញាប់មានរយៈពេលវែង មុនពេលដែលសវនាការអង្គសេចក្តីចាប់ផ្តើម។ ក្នុងប្រព័ន្ធបែបនេះ ការពិគ្រោះលើភស្តុតាងកើតមានឡើងនៅក្នុងដំណាក់កាលជំនុំជម្រះដល់អង្គសេចក្តី មិនមែនក្នុងដំណាក់កាលស៊ើបអង្កេតនោះទេ។ ដូច្នេះ វាគ្រាន់តែជាការចាំបាច់ដើម្បីផ្តល់នូវភស្តុតាងដាក់បន្ទុក ជាភាសារបស់ជនជាប់ចោទនៅដំណាក់កាលនៃនីតិវិធីនេះ។ ជាងនេះទៅទៀត សូម្បីតែរដ្ឋអាជ្ញាមិនជាប់កាតព្វកិច្ចត្រូវផ្តល់នូវសម្ភារៈដោះបន្ទុកទៅអោយជនជាប់ចោទជាភាសារបស់ខ្លួនផ្ទាល់ មេធាវីការពារគឺយ៉ាងហោចណាស់ត្រូវបានផ្តល់អោយនូវធនធាន និង ពេលវេលានៅមុនពេលសវនាការដើម្បីរៀបចំការបកប្រែដោយខ្លួនឯង អញ្ចឹងគឺដើម្បីគាំទ្រនូវសិទ្ធិមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំកិច្ចការពារក្តី។ ប្រព័ន្ធនេះគឺពឹងផ្អែកទៅលើ សមភាពនៃការតទល់ក្តីរវាងរដ្ឋអាជ្ញា និងមេធាវីការពារ ជាមួយនឹងកាតព្វកិច្ចបន្តិចបន្តួចទៅលើរដ្ឋអាជ្ញា ដែលថ្លឹងថ្លែងដោយផ្តល់នូវធនធានបន្ថែមដែលសំខាន់ដល់មេធាវីការពារ។

17. ផ្ទុយពីនេះ នៅ អ.វ.ត.ក ការស៊ើបសួរគឺស្ថិតការគ្រប់គ្រងទាំងស្រុងរបស់ ក.ស.ច.ស ជាមួយតួនាទី និងកាតព្វកិច្ចរបស់ ក.ស.ព និង មេធាវីការពារ ត្រូវបានកាត់បន្ថយដោយប្រៀបធៀបទៅនឹងតួនាទីរបស់ពួកគេ នៅ តុលាការពិសេសចំពោះកិច្ច (ad hoc)។ ក្រោមវិធាន ៥៥(៥) ក.ស.ច.ស "ត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកក៏ដោយ" ។ សិទ្ធិរបស់មេធាវីការពារដើម្បីធ្វើការស៊ើបអង្កេតដោយខ្លួនឯងមានកំរិត ដោយសារ ក.ស.ច.ស ទទួលបន្ទុកក្នុងការស្វែងរកភស្តុតាងដែល "បង្ហាញ ឬ ទោរទន់ទៅរកការបង្ហាញភាពគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ" ឬ បន្ធូរបន្ថយនូវពិរុទ្ធភាពរបស់ជនជាប់ចោទ ឬ ដែលអាចប៉ះពាល់ដល់ភាពជឿរជាក់បាននូវភស្តុតាងរបស់អយ្យការ[19]។ នៅក្នុងកាលៈទេសៈបែបនេះ នៅពេលដែលមានតែ ក.ស.ច.ស ដែលមានសិទ្ធិ និង កាតព្វកិច្ចដើម្បីធ្វើកិច្ចស៊ើបសួរ វាជាការរំលោភបំពាននូវសិទ្ធិរបស់លោក អៀង សារី ដើម្បីចូលរួមនៅក្នុងកិច្ចការពារក្តីរបស់ខ្លួន ក្នុងការបដិសេធនូវការបកប្រែនូវលទ្ធផលនៃការស៊ើបសួរនោះ។

18. ក្នុងទំហំនៃករណីដែលដកស្រង់ដោយ ក.ស.ច.ស អាចអនុវត្តបាននៅ អ.វ.ត.ក មេធាវីការពារសូមកត់សំគាល់ថា ករណីដែលបានដកស្រង់ទាំងនោះពិតជាមិនមែនគាំទ្រនូវកាតព្វកិច្ចដ៏មានកំរិត

---

[18] មាត្រា ១៩(២) នៃច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY

[19] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី ១៧ កក្កដា ១៩៩៨ A/CONF.183/9 មាត្រា ៦៧(២)។

ក្នុងការបកប្រែដែលសន្និដ្ឋានដោយ ក.ស.ច.ស ឡើយ។ ការពិត សេចក្តីក្នុងរឿង *Ljubičić* បន្ថែមទៅលើការបង្គាប់អោយបកប្រែនូវភស្តុតាងបញ្ជាក់ពីភាពមាន ឬគ្មានពិរុទ្ធ ក៏សំអាងផងដែរថា "ផ្អែកលើអានុភាពនៃការអនុវត្តតាមផ្លូវតុលាការដែលមានស្រាប់ បទដ្ឋានទូទៅបច្ចុប្បន្នទាក់ទងនឹងការបកប្រែឯកសារក្នុងដំណាក់កាលមុនអង្គសេចក្តីតម្រូវថា ឯកសារតទៅនេះដែលត្រូវដាក់ជូនជនជាប់ចោទជាភាសាដែលខ្លួនគេអាចយល់បាន [...] ដូចជា ឯកសារដោះបន្ទុកដែលបង្ហាញដោយរដ្ឋអាជ្ញា យោងទៅតាមមាត្រា ៦៨ នៃវិធាន[20]"។ ហេតុដូច្នេះ ទៅបីជាសេចក្តី *Ljubičić* គាំទ្រនូវការបញ្ចូលនូវភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធ ជាភាសារបស់ជនជាប់ចោទ សេចក្តីសម្រេចនេះមិនបានកំរិតទៅដល់កាតព្វកិច្ចបែបនោះឡើយ។

19. ហេតុដូច្នេះ មេធាវីការពារសូមស្នើថា បើមានតែការបកប្រែ ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធ ក.ស.ច.ស កំពុងរំលោភបំពាននូវសិទ្ធិរបស់លោក អៀង សារី ដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួន បន្ថែមទៅលើការរំលោភបំនាននូវតួនាទីអនាគតិរបស់ខ្លួននៅដែលខ្លួនបកប្រែតែភស្តុតាងដាក់បន្ទុក។

## B. ការបកប្រែនូវឯកសារជាភាសារបស់មេធាវីបរទេស

20. ដីកាសម្រេចរំលឹកឡើងវិញថាលោក អៀង សារី នៅក្នុងលិខិតចុះថ្ងៃទី ៦ ឧសភា ២០០៨ បានស្នើសុំថា រាល់ឯកសារគាំទ្រការចោទប្រកាន់ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ត្រូវបកប្រែជាភាសាអង់គ្លេស[21]។ វាក៏បានពន្យល់ផងដែរថា ឯកសារដែលត្រូវបកប្រែជាភាសាខ្មែរ ដូចមានចែងក្នុងផ្នែក ខ នៃ ដីកាសម្រេចស្តីពីការបកប្រែ គួរត្រូវបានបកប្រែជាភាសាប្រើការផ្លូវការរបស់ អ.វ.ត.ក មានដូចជា ភាសាអង់គ្លេស និងបារាំង។ ដូច្នេះ ក.ស.ច.ស បានបដិសេធនូវសំណើរបស់មេធាវីការពារ សុំអោយបកប្រែជាភាសាអង់គ្លេសនូវឯកសារដែលបានដកស្រង់នៅក្នុង កំណត់សំគាល់ផ្នែកខាងក្រោមនៃទំព័រនៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។ ក.តរ.ព.តរ ក៏បានបដិសេធផងដែរមិនបកប្រែជាភាសាអង់គ្លេសនូវភស្តុតាងដោះបន្ទុក ដែលមិនបង្កបង្កើតបានជា ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព។

---

[20] សេចក្តីសម្រេចករណី *Ljubičić* នៅចំនុច ៣ ។

[21] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ១ និង ២ ។

00207580



21. មេធាវីការពារសូមស្នើថា ដោយបដិសេធនូវការបង្គាប់អោយបកប្រែនូវ ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធ ជាភាសាអង់គ្លេស រហូត ទាល់ដល់ចុងបញ្ចប់នៃកិច្ចស៊ើបសួរ និង បដិសេធនូវការបង្គាប់ការបកប្រែសំណុំរឿងដែលមិនបង្កបង្កើតបានជា ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព ដីកាសម្រេចស្តីពីការបកប្រែ នឹងរារាំងលោក អៀង សារី ពីការការពារក្តីប្រកបដោយប្រសិទ្ធិភាព ទូទាំងនីតិវិធីនៃដំណាក់កាលស៊ើបសួរ។

22. តាមមាត្រា ២៤ នៃច្បាប់បង្កើត អ.វ.ត.ក "ក្នុងកំឡុងពេលនៃការស៊ើបអង្កេត ជនសង្ស័យត្រូវមានសិទ្ធិដោយគ្មានលក្ខខណ្ឌក្នុងការទទួលបានជំនួយពីមេធាវី តាមការជ្រើសរើសរបស់ខ្លួន"។ សិទ្ធិនេះជាគោលការណ៍ចម្បងមួយ ដែលផ្អែកតាមនេះសិទ្ធិដទៃទៀតរបស់លោក អៀង សារី ត្រូវបានគេគាំទ្រ ខណៈដែលវាជាញឹកញាប់មានតែតាមរយៈការការពារដោយមេធាវីទើបសិទ្ធិដទៃទៀតនោះត្រូវតែបានគេការពារ។ វាជាការច្បាស់លាស់ដែលថា សិទ្ធិទទួលជំនួយការពារក្រោមបទបញ្ញត្តិនេះ មិនត្រឹមតែអនុវត្តនៅនីតិវិធីជំនុំជម្រះប៉ុណ្ណោះទេ ប៉ុន្តែធានាថា លោក អៀង សារី មានសិទ្ធិទទួលបានជំនួយការពារ "ក្នុងអំឡុងពេលស៊ើបសួរ"។ ដោយគ្រាន់តែបង្គាប់ការបកប្រែនូវអ្វីដែលសន្មតថាជា "ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព" ជាភាសាអង់គ្លេសនៅពេលដែលដីកាដំណោះស្រាយត្រូវគេចេញក្រោមវិធាន ៦៧(១) ដីកាសម្រេចនេះរារាំងលោក អៀង សារី ពីការទទួលបានជំនួយដ៏មានប្រសិទ្ធិភាព ទៅលើបញ្ហាជាខ្លឹមសារនៅក្នុងដំណាក់កាលស៊ើបសួរ។

23. មេធាវីការពារសូមស្នើបន្ថែមថា ឃ្លា "មានសិទ្ធិដោយគ្មានលក្ខខណ្ឌក្នុងការទទួលបានជំនួយពីមេធាវី" នៅក្នុងមាត្រា ២៤ បង្ហាញនូវសារៈសំខាន់នៃសិទ្ធិមានមេធាវីប្រកបដោយប្រសិទ្ធិភាព ដើម្បីអោយសិទ្ធិនេះមានន័យ[22]។ នៅក្នុងកាលៈទេសៈនៃការស៊ើបសួរប្រឆាំងលោក អៀង សារី មេធាវីការពារសូមស្នើថា វាមានសារៈសំខាន់បំផុតសំរាប់សហមេធាវីបរទេសដើម្បីអាចពិនិត្យ និងវិភាគនូវរាល់ភស្តុតាងទាំងអស់ដែលគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ដើម្បីមានលទ្ធភាពជួយ និងផ្តល់ប្រឹក្សាដ៏មានប្រសិទ្ធិភាពលោក អៀង សារី ។ បើសិនជាសហមេធាវី មិនមានលទ្ធភាពដើម្បីត្រួតពិនិត្យថាតើ ឯកសារគាំទ្រការចោទប្រកាន់ដែលដាក់បញ្ចូលដោយ ក.ស.ព ឬ ថាតើវាគួរឈានទៅរកផ្លូវផ្សេងក្នុងការស៊ើបសួរដែរឬទេ នោះវានឹងទៅជាការមិនអាចទៅរួចក្នុងការប្រើប្រាស់សិទ្ធិដើម្បីផ្តល់ការពារប្រកបដោយប្រសិទ្ធិភាពដល់លោក អៀង សារី។

[22] *សូមមើល រឿងក្តី Artico តទល់នឹង ប្រទេសអ៊ីតាលី* តុលាការអឺរុបសម្រាប់សិទ្ធិមនុស្ស ចុះថ្ងៃទី ៣០ មេសា ១៩៨០ កថាខណ្ឌ ៣៣ ។

24. ជាដំបូង សិទ្ធិតតាំងនៅដំណាក់កាលណាមួយក្នុងនីតិវិធីគឺ វិធីដំបូងនៃការធ្វើតេស្តសំរាប់ដីកាឃុំខ្លួនបណ្តោះអាសន្ន ដែលគេហៅថា "មានមូលហេតុដែលត្រូវបានរកឃើញ និង ជឿរជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម[23]" ក្លាយជារឿងមិនអាចទៅរួច។ ដោយសារមិនមានលទ្ធភាពពិនិត្យភស្តុតាងជាភាសាដែលមេធាវីអាចយល់បាន វាមិនអាចទៅរួចក្នុងការតតាំងនឹងអង្គហេតុជាមូលដ្ឋានសំរាប់ចោទប្រកាន់បទល្មើស ដូច្នេះហើយ នេះគឺកំរិតយ៉ាងទាបបំផុតនូវលទ្ធភាពដើម្បីតតាំងនឹងការឃុំឃាំង។

25. ទីពីរ ការ ខកខានរបស់ ក.ស.ច.ស មិនបកប្រែនូវ *"ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព"* រហូតដល់ចុងបញ្ចប់នៃកិច្ចស៊ើបសួរ រារាំងជាខ្លាំងដល់មេធាវីការពារពីលទ្ធភាពស្នើ "ក.ស.ច.ស សុំអោយចេញបង្គាប់បែបនេះ ឬ បំពេញកិច្ចស៊ើបសួរបែបនេះ នៅពេលដែលគេយល់ថាវាចាំបាច់សំរាប់ការធ្វើកិច្ចស៊ើបសួរនេះ[24]"។ ការខកខានមិនស្នើសុំអោយបំពេញកិច្ចស៊ើបសួរនៅក្នុងរយៈពេលនៃដំណាក់កាលស៊ើបសួរ ដោយសារសហមេធាវីបរទេសមិនអាចមានលទ្ធភាពយល់ពីអត្ថន័យ និងសារៈសំខាន់នៃឯកសារដែលអាចដកហូតលោក អៀង សារី ពីសិទ្ធិទទួលបានការស៊ើបអង្កេតយ៉ាងពេញលេញលើរឿងក្តីរបស់គាត់។

26. ទាក់ទងទៅនឹងការបកប្រែនូវឯកសារដោះបន្ទុក ឬឯកសារដែលបង្កើតជាផ្នែកមួយនៃសំណុំរឿង ប៉ុន្តែមិនបានរួមផ្សំជា ភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព មេធាវីសូមស្នើថា ការរិះគន់ដូចគ្នាអនុវត្តនៅពេលដែលត្រូវបានគេពិភាក្សាខាងលើទាក់ទងនឹងការបកប្រែនូវឯកសារទាំងនេះជាភាសាខ្មែរ[25]។ ជាលទ្ធផលនៃការខកខានមិនបកប្រែជាភាសាអង់គ្លេសគឺរំលោភបំពានសិទ្ធិទទួលការការពារក្តីដោយមានប្រសិទ្ធិភាពរបស់លោក អៀង សារី ដោយសហមេធាវីរបស់គាត់។

---

[23] វិធានផ្ទៃក្នុង ៦៣(៣)(ក) ។ វិធានផ្ទៃក្នុង ៦៤(៣) ប្រសិនបើស្ថានភាពផ្លាស់ប្តូរ ចាប់ពីពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទអាចដាក់ពាក្យសុំជាថ្មីម្តងទៀត ក្នុងរយៈពេលមិនតិចជាង ៣(បី)ខែ បន្ទាប់ពីមានសេចក្តីសំរេចចុងក្រោយ ដែលបដិសេធពាក្យដោះលែងអោយនៅក្រៅឃុំ ។ ហេតុដូច្នេះ ទោះបីជា ដីកាឃុំខ្លួនបណ្តោះអាសន្នដែលត្រូវបានគេប្តឹងឧទ្ធរណ៍ត្រូវបានចេញថ្ងៃទី ១៤ វិច្ឆិកា ២០០៧ ក៏លោក អៀង សារី នឹងអាចតតាំងការឃុំខ្លួនគាត់ នៅរយៈពេលបីខែបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរួចមក។

[24] វិធានផ្ទៃក្នុង ៥៥(១០) ។

[25] *សូមមើលការយោងខាងមុខ* កថាខណ្ឌ ៩ ដល់ ១៩ ។

## C. ការរំលោភបំពានទូវសមភាពនៃការតទល់ក្តីដោយប្រព័ន្ធបកប្រែបង្គាប់ដោយ ក.ស.ច.ស

27. ក្រៅពីការបដិសេធដោយ ក.ស.ច.ស នូវសំណើរបស់មេធាវីសុំអោយបកប្រែនូវរាល់ឯកសារទាំងអស់ដែលភ្ជាប់មកជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ជាភាសាអង់គ្លេស និងខ្មែរ ក.ស.ច.ស បានពិចារណាថា៖

> "ក្រុមមេធាវីការពារម្នាក់ៗគួរមានដោយខ្លួនឯង កាន់តែឆាប់កាន់តែប្រសើរ នូវជំនួយការដោយអ្នកប្រែម្នាក់ដោយមិនគិតថ្លៃ និងពេញម៉ោង (រវាងភាសាផ្លូវការដែលត្រូវកំណត់ដោយក្រុមមេធាវីការពារ) ដើម្បីធានាថា ជនត្រូវចោទ និងក្រុមមេធាវីការពារអាចមានឯកសារដែលត្រូវបានបកប្រែតាមតម្រូវការ ដើម្បីវាយតម្លៃនូវសេចក្តីត្រូវការបកប្រែដោយក្រុមមេធាវីសំរាប់ការបញ្ជូនទៅផ្នែកគ្រប់គ្រងតុលាការ និងដើម្បីជួយដល់ក្រុមមេធាវីដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយផ្នែកគ្រប់គ្រងតុលាការ[26]"។

28. អ្នកបកប្រែនេះនឹងត្រូវតែងតាំងសំរាប់ "រយៈពេល២ខែជាប់លាប់ប៉ុន្តែអាចធ្វើជាថ្មីបាន [...] ។ ការបន្តែមនូវការតែងតាំងនេះគឺជាឆន្ទានុសិទ្ធិរបស់ការិយាល័យរដ្ឋបាល បន្ទាប់ពីពិគ្រោះជាមួយសហចៅក្រមស៊ើបអង្កេត[27]"។

29. ប្រព័ន្ធដែលកំណត់ដោយ ក.ស.ច.ស ដែលមិនងាយនឹងសំរេចបាននូវគោលដៅសន្សំសំចៃរបស់តុលាការលើកឡើងដោយ ក.ស.ច.ស[28] នោះ គឺជាការខ្វះខ្នាយ និងរំលោភបំពានដល់ គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីគ្នា (equality of arms) ដោយផ្ទេរបន្ទុកក្នុងការរៀបចំការបកប្រែពីអាជ្ញាធររដ្ឋមកលើបុគ្គលឯកជនវិញ។

30. ទីមួយ ដោយផ្តល់អោយនូវអ្នកបកប្រែម្នាក់មួយៗដល់ក្រុមមេធាវីទាំងប្រាំផ្សេងគ្នា ដើម្បីបកប្រែអោយមានប្រសិទ្ធិភាពនូវឯកសារដដែលដូចគ្នា ក.ស.ច.ស ទំនងជាធ្វើអោយការងាររបស់អ្នកបកប្រែមានការជាន់គ្នា។ មេធាវីការពារយល់ឃើញថាមានការពិបាកយល់ ថាតើវាមិនមានប្រសិទ្ធិភាពទេឬនៅពេលបញ្ចូលរួមគ្នាពីធនធានផ្សេងៗគ្នានៃផ្នែកបកប្រែ ដើម្បីបកប្រែនូវឯកសារ

---

[26] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ៦ ដល់ ៧ ។

[27] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ៨ ។

[28] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ៤ ដកស្រង់យករឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sarić*, IT-95-9, សេចក្តីសម្រេចចុះថ្ងៃទី ២១ ឧសភា ១៩៩៨ ។

ដែលដាក់ជូនដោយ ក.ស.ព ដើម្បីគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ជាជាងផ្តល់អោយក្រុមមេធាវីនីមួយៗនូវអ្នកបកប្រែម្នាក់នោះ។ នៅពេលដែលអ្នកបកប្រែម្នាក់ៗដែលបានផ្តល់មកក្រុមមេធាវី "តម្រូវអោយប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរក្សាការសម្ងាត់យ៉ាងតឹងរឹងបំផុតដែលទាក់ទងនឹងសារជាតិ និងខ្លឹមសារនៃការងាររបស់ពួកគេក្នុងអំឡុងពេលចាត់តាំងនេះ[29]" ដោយសមហេតុសមផល អ្នកបកប្រែនឹងមិនអាចចែកចាយនូវការបកប្រែដែលពួកគេបានធ្វើជាមួយក្រុមមេធាវីការពារឡើយ។ ដូច្នេះ អ្នកបកប្រែទាំងប្រាំនាក់អាចនឹងត្រូវបកប្រែដំណាលគ្នាលើឯកសារតែមួយដូចគ្នា។

31. បើសិនអ្នកបកប្រែដែលផ្តល់មកគ្រាន់តែបកប្រែដោយផ្ទាល់មាត់ជាជាងដោយការសរសេរ នេះគឺមិនអាចជួយអ្វីបានដល់សហមេធាវីបរទេស ដែលមិនបានស្ថិតនៅក្រុងភ្នំពេញឡើយ។ វាក៏មានន័យផងដែរថា លុះត្រាណាតែសារៈសំខាន់នៃឯកសារមួយដែលគេទទួលស្គាល់ភ្លាមៗដោយបុគ្គលម្នាក់ដែលត្រូវគេបកប្រែដោយផ្ទាល់មាត់អោយ នោះវាក្លាយជាការមិនមានប្រសិទ្ធិភាព។ រឿងនេះជាញឹកញាប់គឺវាដូច្នេះ ដែលសំណុំរឿងដែលមានភាពស្មុគស្មាញ និងមានទំហំធំធេងដូចជាសំណុំរឿងដែលកំពុងត្រូវបានចោទប្រកាន់ចំពោះមុខ អ.វ.ត.ក សារៈសំខាន់នៃផ្នែកនីមួយៗនៃភស្តុតាងកាន់តែលេចឡើងនៅពេលទាក់ទងជាមួយផ្នែកដទៃទៀតនៃភស្តុតាង។ ហេតុដូច្នេះ មានតែការបកប្រែដោយសរសេរប៉ុណ្ណោះទើបមានលក្ខណៈគ្រប់គ្រាន់ ដើម្បីអាចប្រៀបធៀបរវាងឯកសារមួយប្រឆាំងនឹងឯកសារមួយទៀត ។

32. ការខ្ជះខ្ជាយពេលវេលា និងធនធានលេចឡើងផ្ទុយគ្នាទាំងស្រុងនឹងមូលហេតុដែលគាំទ្រដីកាសម្រេច។ ផ្ទុយទៅវិញ បើអ្នកបកប្រែរួមគ្នា និងជាខ្សែសង្វាក់បកប្រែសរសេរនូវឯកសារទាំងអស់ដែលគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ការងារជាន់គ្នានេះនឹងមិនកើតមានទេ ហើយពួកគេនឹងមានលទ្ធភាពបង្កើនអត្ថបទបកប្រែច្រើនក្នុងម្នាក់ៗ។ បន្ថែមពីនេះ ខណៈដែលអ្នកបកប្រែត្រូវបានផ្តល់មកក្នុងរយៈពេលតែ២ខែ វាទំនងជាមានការងារតិចតួចត្រូវសំរេចក្នុងរយៈពេលដ៏ខ្លីបែបនេះ ក្នុងការរួមចំណែកទៅក្នុងតម្រូវការបកប្រែរបស់ក្រុមមេធាវីនីមួយៗ។ ដីកាសម្រេចអនុញ្ញាតអោយមានការបន្ថែមពេលវេលានេះ ប៉ុន្តែវាអាស្រ័យទៅលើ"ឆន្ទានុសិទ្ធិរបស់ការិយាល័យ

[29] *សូមមើល* លិខិតចុះថ្ងៃទី ១៥ កក្កដា ២០០៨ ពីលោក ក្រាញ់ តូនី ប្រធានផ្នែកគ្រប់គ្រងតុលាការ ផ្ញើរមកកាន់លោក Rupert Skilbeck ប្រធានអង្គភាពគាំពារការការពារក្តី ដែលមានចំណងជើងថា "ការចាត់តាំងអ្នកបកប្រែអនុលោមទៅតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ១៩ មិថុនា ២០០៨" ។ មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ ក ។

រដ្ឋបាល[30]" ដោយមិនមានចែងពីលក្ខណៈវិនិច្ឆ័យថាតើពេលណាការសុំបន្ថែមនូវរយៈពេល២ខែនេះ អាចនឹងត្រូវបដិសេធ។

33. ទីពីរ ប្រព័ន្ធដែលបង្កើតឡើងដោយ ក.ស.ច.ស បញ្ច្រាសនូវបន្ទុកបកប្រែមកលើក្រុមមេធាវីវិញ ជាជាងដាក់ទៅលើអាជ្ញាធររបស់រដ្ឋ ដូចជា ក.ស.ព និង ក.ស.ច.ស ។ វិធីសាស្ត្របែបនេះផ្តល់ការយល់ខុសដោយភ័ន្តច្រលំជាមូលដ្ឋានទៅលើច្បាប់សិទ្ធិមនុស្ស ដែលការពារសិទ្ធិរបស់បុគ្គលប្រឆាំងនឹងអំណាចរបស់រដ្ឋ និងដូច្នេះហើយដាក់កាតព្វកិច្ចជាវិជ្ជមានលើអាជ្ញាធររបស់រដ្ឋអោយការពារសិទ្ធិមនុស្សរបស់ជនជាប់ចោទ។

34. ច្បាប់សិទ្ធិមនុស្សចែងអំពីទំនាក់ទំនងរវាងបុគ្គលឯកជន និងរដ្ឋ ដោយបង្កើតអោយមានកាតព្វកិច្ចជាវិជ្ជមានមកលើរដ្ឋដើម្បីការពារ សិទ្ធិដែលត្រូវបានធានារបស់បុគ្គលឯកជន។ គោលការណ៍ដ៏ចម្បងនេះគឺឆ្លុះបញ្ចាំងតាមរយៈកតិកាសញ្ញា ICCPR ដែលចងភ្ជាប់ប្រទេសកម្ពុជាក្រោមរដ្ឋធម្មនុញ្ញរបស់ខ្លួន[31]។ ក្នុងន័យទូទៅ គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុបនៃអង្គការសហប្រជាជាតិ ("គណៈកម្មធិការ UNHRC") បានថ្លែងថា តាមរយៈមាត្រា ២ នៃកតិកាសញ្ញា ICCPR "កាតព្វកិច្ចទូទៅមួយគឺត្រូវបានដាក់លើបណ្តារដ្ឋជាភាគីដើម្បីគោរពសិទ្ធិក្នុងកតិកាសញ្ញានេះ និងធានាសិទ្ធិទាំងនេះដល់បុគ្គលទាំងអស់នៅក្នុងដែនដីរបស់ខ្លួន និងដែលជាកម្មវត្ថុនៃយុត្តាធិការរបស់ខ្លួន[32]"។

35. ទាក់ទងទៅនឹងករណីបច្ចុប្បន្ន កាតព្វកិច្ចបកប្រែជាកម្មសិទ្ធិរបស់ ក.ស.ព និង ក.ស.ច.ស ។ គណៈកម្មធិការ UNHRC បានថ្លែងថា "កាតព្វកិច្ចនៃកតិកាសញ្ញាជាទូទៅ និង ជាពិសេស មាត្រា ២ គឺចងភ្ជាប់ទាំងស្រុងដល់បណ្តារដ្ឋនីមួយៗ ។ សាខាទាំងអស់របស់រដ្ឋាភិបាល (និតិប្រតិបត្តិ នីតិបញ្ញត្តិ និង តុលាការ) និងអាជ្ញាធរសាធារណៈ និងរដ្ឋាភិបាល គ្រប់ជាន់ថ្នាក់ (ទាំងថ្នាក់មូលដ្ឋាន តំបន់ និងថ្នាក់ជាតិ)" ស្ថិតក្នុងឋានៈដែលចូលរួមចំណែកទទួលខុសត្រូវរបស់រដ្ឋជា

---

[30] ដីកាសម្រេចស្តីពីការបកប្រែ ចំណុច ៨ ។

[31] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុង... កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស"។ ប្រទេសកម្ពុជាចុះហត្ថលេខា និងផ្តល់សច្ចាប័នដល់កតិកាសញ្ញា ICCPR នៅថ្ងៃទី ១៧ តុលា ១៩៨០ និង ២៦ ឧសភា ១៩៩២ ជាបន្តបន្ទាប់។

[32] ការអត្ថាធិប្បាយទូទៅ (General Comment) លេខ ៣១ សារជាតុនៃកាតព្វកិច្ចផ្លូវច្បាប់ទូទៅដែលដាក់លើរដ្ឋជាភាគីនៃកតិកាសញ្ញ ចុះថ្ងៃទី ២៩ មីនា ២០០៤ ("ការអត្ថាធិប្បាយលេខ ៣១") កថាខណ្ឌ ៣ ។

ភាគី[33]"។ នេះមានន័យថា ទាំងចៅក្រម សហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក ត្រូវជាប់កាតព្វកិច្ចការពារសិទ្ធិរបស់លោក អៀង សារី។

36. ដូចមេធាវីការពារបានគូសចំណាំបង្ហាញ ក.ស.ច.ស នៅក្នុងលិខិតរបស់ខ្លួនថា៖

> មេធាវីការពារយល់ឃើញថាការជាប់គាំងក្នុងការបកប្រែឯកសារ គឺជាការទទួលខុសត្រូវដោយផ្ទាល់របស់ ក.ស.ព ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលបញ្ជូនទៅ ក.ស.ច.ស ដោយ ក.ស.ព បានអះអាងថា គាំទ្រដោយឯកសារប្រមាណជា ១៦.០០០ ទំព័រ ដែលជាភាគច្រើនស្ថិតក្នុងភាសាមួយក្នុងចំណោមភាសាជាភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក ។ មេធាវីការពារអះអាងថា កាតព្វកិច្ចក្នុងការបកប្រែឯកសារទាំងអស់នេះគឺជាបន្ទុកផ្ដាច់មុខរបស់ ក.ស.ព។ ប្រសិនបើឯកសារទាំងអស់នេះមិនទាន់បានបកប្រែចប់សព្វគ្រប់ទេ នោះ ក.ស.ព មិនគួរបញ្ជូនដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរឡើយ[34] ។

37. ក.ស.ច.ស ជ្រើសរើសមិនយកតាមការសំណើនៅក្នុងលិខិតនោះដែល "ឲ្យអញ្ជើញ ក.ស.ព ដកចេញនូវឯកសារមួយចំនួន ដែលគាំទ្រដល់ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលមិនមានការពាក់ព័ន្ធស៊ីជម្រៅដល់ការចោទប្រកាន់ទាំងនោះ[35]"។ ខណៈដែលទទួលស្គាល់ថា ក.ស.ច.ស គឺជាសាខាមួយផ្សេងពីអាជ្ញាធររបស់រដ្ឋមិនដូច ក.ស.ព ដែលមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះការជាប់គាំងនៃការបកប្រែ វាជាការប្រសើរដើម្បីគូសបញ្ជាក់ថា ក.ស.ច.ស មិនអាចលាក់កំបាំងនូវភាពខុសពីគ្នានេះដើម្បីគេចពីការទទួលរបស់ខ្លួនឡើយ។ ដោយប៉ុនប៉ងផ្ទេរការទទួលខុសត្រូវបកប្រែមកលើក្រុមមេធាវីការពារ ក.ស.ច.ស គឺកំពុងផ្ទេរបន្ទុកដែលមិនអាចអនុញ្ញាតអោយបានរបស់ខ្លួនមកលើលោក អៀង សារី។

38. ដូចដែល ក.ស.ច.ស ទទួលយក គឺថា សហព្រះរាជអាជ្ញាបានបន្ថែមធនធានមនុស្សរបស់ខ្លួនដោយប្រៀបធៀបជាមួយក្រុមមេធាវីការពារ។ ការដាក់បន្ទុកបកប្រែមកលើលោក អៀង សារី

---

[33] ការអត្ថាធិប្បាយលេខ ៣១ កថាខណ្ឌ ៤ ។

[34] លិខិតថ្ងៃ ៦ ឧសភា ២០០៨ កថាខណ្ឌ ៤ ។

[35] លិខិតថ្ងៃ ៦ ឧសភា ២០០៨ កថាខណ្ឌ ៧ ។

នឹងបង្កបង្កើតបានជាការរំលោភបំពាន គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីគ្នា (equality of arms) ដែលតម្រូវអោយថែរក្សានូវតុល្យភាពដោយយុត្តិធម៌រវាងគូរភាគី[36]។

## IV. សេចក្តីសន្និដ្ឋាន និង ការស្នើសុំដំណោះស្រាយ

39. ដីកាសម្រេចនៅគ្រប់ទិដ្ឋភាពទំនងជាតាក់តែងឡើងដោយពិចារណាអំពី ការសន្សំសំចៃរបស់តុលាការ និងបញ្ហាខ្វះខាតថវិការ និង ជាការប៉ុនប៉ងដោះសារ និងបិទបាំងនូវការខកខានរបស់ ក.ស.ព មិនបានបកប្រែនូវឯកសារគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ នៅមុនពេលដែលដាក់ឯកសារទាំងនេះនៅចំពោះមុខ ក.ស.ច.ស ។ មេធាវីការពារសូមស្នើថា បើសិនជា អ.វ.ត.ក មិនទាន់រៀបចំខ្លួនរួចជាស្រេចដើម្បីផ្តល់នូវសវនាការប្រកបដោយយុត្តិធម៌ និងមិនលំអៀង ដូច្នេះគេមិនត្រូវចេញដីកាចាប់ខ្លួន និងឃុំឃាំងជាបណ្តោះអាសន្នលើរូបលោក អៀង សារី ឡើយ។

អាស្រ័យដោយមូលហេតុដូចបានលើកឡើងនៅទីនេះ មេធាវីការពារសូមស្នើសុំដោយក្តីគោរពដល់ អង្គបុរេជំនុំជម្រះដើម្បី៖

ក. ទុកជាមោឃៈ "ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" របស់ ក.ស.ច.ស ចុះថ្ងៃទី ១៩ មិថុនា ២០០៨ ។

ខ. សំរេចបង្គាប់ផ្នែកគ្រប់គ្រងតុលាការ អោយបកប្រែជាបន្ទាន់នូវរាល់ឯកសារទាំងអស់ដែលបានដាក់ជូនដោយ ក.ស.ព ក្នុងការគាំទ្រដល់ការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។

គ. សំរេចបង្គាប់ផ្នែកគ្រប់គ្រងតុលាការ អោយបកប្រែនូវរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿងដោយមិនគិតថា តើឯកសារទាំងនោះនឹងបង្កើតបានជាភស្តុតាងបញ្ជាក់ពីភាពមានឬគ្មានពិរុទ្ធភាព នោះទេ។

---

[36] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić *et al.*, IT-96-21-T, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំអោយចេញដីកាសម្រេចបង្គាប់អោយបង្ហាញជាមុននូវសាក្សីរបស់មេធាវីការពារ ចុះថ្ងៃទី ៤ កុម្ភៈ ១៩៩៨ កថាខណ្ឌ ៤៥ ។

00207587

A 190/II/1

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ)

សូមអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៨

អាង ឧត្តម　　　　Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី